# អាយស៊ីស៊ីប៊ីយ៉ន



និទ្នាការមួយនៅក្នុងចំណោមនិន្នាការពេលបច្ចុប្បន្នសម្រាប់វិស័យអភិវឌ្ឍន៍ គឺការកើនឡើងនូវលក្ខខណ្ឌពីដៃគូគាំទ្រស្របគ្នាជាមួយ នឹង ការទាមទារកាន់តែខ្លាំងឡើងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តច្បាប់ និងការធ្វើរបាយការណ៍។ នៅពេលជាមួយគ្នានេះផងដែរ ផ្នែកសង្គម និងផ្នែកបច្ចេកវិទ្យាក៏មានការរីកលូតលាស់ដែលជាហេតុនាំឲ្យមានឱកាសសមគួរថ្មីៗសម្រាប់វិស័យអភិវឌ្ឍន៍ ប្រើប្រាស់ផ្នែកទាំងនេះ។ ក្នុងនាមជាអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល អាយស៊ីស៊ី មើលឃើញថា វាជាកាតព្វកិច្ច និងឱកាសដើម្បីជួយ ឧទាហរណដូចជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងក្រុមជំនុំក្នុងស្រុក ដើម្បីធ្វើការឆ្លើយតបទៅនឹងនិន្នាការ។ អង្គការអាយស៊ីស៊ី ក៏មានបទពិសោធន៍ ជិត៣០ឆ្នាំនៅក្នុងវិស័យអភិវឌ្ឍន៍ផងដែរ ក្នុងការចែករំលែកបទពិសោធន៍ទៅកាន់អង្គការសង្គមស៊ីវិលក្នុងស្រុកដ៏ទៃទៀត។ ដូច្នេះ កម្មវិធីថ្មីមួយត្រូវបានបង្កើតឡើងដែលមានឈ្មោះថា **អាយស៊ីស៊ីប៊ីយ៉ន** គឺជាកម្មវិធីផ្ដល់ប្រឹក្សាយោបល់ក្នុងគោលបំណងពង្រឹងសង្គមស៊ីវិល តាមរយៈការបណ្ដុះបណ្ដាល មគ្គុទេសក៍ និងការបង្វឹកបង្រៀន។

រហូតមកដល់ពេលនេះ អង្គការអាយស៊ីស៊ី ទទួលបានបទពិសោធន៍ដំបូងជាមួយនឹងកម្មវិធី**អាយស៊ីស៊ីប៊ីយ៉ន** តាមរយៈការផ្ដល់ប្រឹក្សាយោបល់ និងការបណ្ដុះបណ្ដាលដល់អតិថិជន។ អាយស៊ីស៊ីប៊ីយ៉ន បានធ្វើការជួយដល់អតិថិជនក្នុងស្ថាប័នមួយក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្មី។ ចំពោះអតិថិជនក្នុងស្ថាប័នមួយផ្សេងទៀត **អាយស៊ីស៊ីប៊ីយ៉ន** បានធ្វើការផ្ដល់ជាយោបល់ លើសេចក្ដីព្រាងស្នើសុំមូលនិធិរបស់ពួកគេ មុនពេលផ្ញើទៅកាន់ដៃគូគាំទ្រ។ បច្ចុប្បន្ននេះ **អាយស៊ីស៊ីប៊ីយ៉ន** បាននឹងកំពុងផ្ដល់នូវការបណ្ដុះបណ្ដាល និងប្រឹក្សាយោបល់ដល់អតិថិជនមួយក្នុងការរៀបចំគម្រោង តាមដាននិងវាយតម្លៃ និងការធ្វើរបាយការណ៍។ តាមរយៈកិច្ចការងារប្រឹក្សាយោបល់របស់**អាយស៊ីស៊ីប៊ីយ៉ន**ទាំងនេះ បានធ្វើឲ្យអាយស៊ីស៊ីជាអង្គការដែលទទួលបានចំណេះដឹងថ្មីៗ និងមានឱកាសក្នុងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងអង្គការសង្គមស៊ីវិលដែលអង្គការអាយស៊ីស៊ីមិនធ្លាប់បានធ្វើការជាមួយពីមុនមក។ ហេតុដូច្នេះ ការរួមបញ្ចូលគ្នាពីការធ្វើការជាមួយអតិថិជនរបស់**អាយស៊ីស៊ីប៊ីយ៉ន** គឺជាអត្ថប្រយោជន៍ដ៏មានតម្លៃសម្រាប់អង្គការអាយស៊ីស៊ី។ អង្គការអាយស៊ីស៊ី នឹងប្រើប្រាស់ការសិក្សា និងកិច្ចសហការនេះដើម្បីពង្រឹងដល់ការងារអភិវឌ្ឍន៍របស់ខ្លួនដែលរួមចំណែកទៅដល់យុទ្ធសាស្ត្រផ្ដោត និងបេសកកម្មរបស់អាយស៊ីស៊ី នៅក្នុងប្រទេសកម្ពុជា។

អង្គការអាយស៊ីស៊ី ជឿជាក់ថាប្រជាជាតិដែលមានការអភិវឌ្ឍន៍ និងប្រជាធិបតេយ្យ គឺត្រូវការវិស័យសង្គមស៊ីវិលដែលអាចមានការគាំទ្រ និងកិច្ចសហការគ្នាជាមួយនឹងវិស័យឯកជន និងរដ្ឋក្នុងលក្ខណៈតម្លាភាព។ ទោះបីជាយ៉ាងណាក៏ដោយ វិស័យសង្គមស៊ីវិលនៅកម្ពុជានៅតែត្រូវការជំនួយ ដើម្បីប្រែក្លាយទៅជាសង្គមស៊ីវិលរឹងមាំ សមត្ថភាពគ្រប់គ្រាន់ និងស្វាហាប់ ក្នុងការលើកកម្ពស់សិទ្ធិមនុស្ស និងយុត្តិធម៌ផ្នែកច្បាប់។ ហេតុដូច្នេះហើយ ទើបកម្មវិធី **អាយស៊ីស៊ីប៊ីយ៉ន** ស្វះស្វែងធ្វើការគាំទ្រវិស័យសង្គមស៊ីវិល ដើម្បីប្រែក្លាយទៅជាតួអង្គដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា តាមរយៈការផ្ដល់ជូននូវសេវាប្រឹក្សាយោបល់ និងបណ្ដុះបណ្ដាលដល់អង្គការសង្គមស៊ីវិល ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សមាគម គ្រឹះស្ថានសាសនា បណ្ដាញ និងសកម្មភាពនានា។

នៅក្នុងអំឡុងឆ្នាំ២០១៨ និង២០១៩ **អាយស៊ីស៊ីប៊ីយ៉ន** កំពុងនឹងផ្ដល់វគ្គសិក្សារយៈពេលមួយថ្ងៃ នូវមុខវិជ្ជាចំនួនបីដែលសមស្របទៅនឹងអង្គការសង្គមស៊ីវិលភាគច្រើន។ មុខវិជ្ជាទាំងនេះរួមមាន "សមភាពយេនឌ័រ" "វិធីសាស្ត្រផ្អែកលើសិទ្ធិ" និង "ការរៀបចំគោលនយោបាយ" ។ **អាយស៊ីស៊ីប៊ីយ៉ន** រីករាយក្នុងការរង់ចាំបើកវគ្គសិក្សាទាំងអស់នេះ និងធ្វើការជាមួយអង្គការសង្គមស៊ីវិលក្នុងស្រុក ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដើម្បីបង្កឲ្យមានកំណើនសេដ្ឋកិច្ច យុត្តិធម៌ផ្លូវច្បាប់សម្រាប់មនុស្សទាំងអស់ និងបំពេញសិទ្ធិប្រជាពលរដ្ឋ។

កាលបរិច្ឆេទ ៖ កក្កដា ២០១៨